## ករណីនាយករដ្ឋមន្ត្រីកម្ពុជា (2023-003-FB-MR)

នៅថ្ងៃទី 8 ខែមករា ឆ្នាំ 2023 ប្រាំពីរខែមុនការបោះឆ្នោតជាតិរបស់ប្រទេសកម្ពុជា វីដេអូបន្តផ្ទាល់មួយត្រូវបានផ្សាយនៅលើទំព័រហ្វេប៊ុក (Facebook) ផ្លូវការរបស់នាយករដ្ឋមន្ត្រីកម្ពុជា ហ៊ុន សែន។ លោក ហ៊ុន សែន បានកាន់អំណាចចាប់តាំងពីឆ្នាំ 1985 ហើយកំពុងត្រៀមទទួលការបោះឆ្នោតសម្រាប់តំណែងនេះឡើងវិញ។ វីដេអូនោះបង្ហាញពី សុន្ទរកថាមួយដ៏វែងដែលថ្លែងដោយ លោកនាយករដ្ឋមន្ត្រី ធ្វើឡើងជាភាសាខ្មែរ ដែលជាភាសាផ្លូវការរបស់កម្ពុជា នៅក្នុងពិធីសម្ពោធបើកការដ្ឋានគម្រោងពង្រីកផ្លូវជាតិក្នុងខេត្តកំពង់ចាម។ នៅក្នុងវីដេអូនោះ លោកឆ្លើយតបទៅនឹងការចោទប្រកាន់ចំពោះគណបក្សប្រជាជនកម្ពុជា (CPP) ដែលជាគណបក្សកាន់អំណាចរបស់លោកថា
បានលួចសន្លឹកឆ្នោតក្នុងការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ 2022។ លោកស្នើសុំឱ្យគណបក្សនយោបាយដែលបានធ្វើការចោទប្រកាន់ផ្សេងៗនោះឱ្យជ្រើសរើសរវាង “ប្រព័ន្ធច្បាប់” និង “ដំបង” ហើយលោកមានប្រសាសន៍ថា ពួកគេអាចជ្រើសរើសប្រព័ន្ធច្បាប់
ឬ លោក “នឹងធ្វើការប្រមូលផ្តុំអ្នកគាំទ្រ CPP ឱ្យធ្វើការតវ៉ា និងវាយអ្នកឯង”។
លោកបន្ថែមទៀតថា “ប្រសិនបើនោះជាសេរីភាពនៃ ការ បញ្ចេញ មតិ ខ្ញុំក៏នឹងសម្តែងនូវសេរីភាពរបស់ខ្ញុំដោយបញ្ជូនមនុស្សទៅកន្លែង និងផ្ទះរបស់អ្នកឯង”។ លោកបញ្ចេញឈ្មោះបុគ្គលមួយចំនួន ដោយព្រមានថា អ្នកទាំងនោះ “ត្រូវការប្រកាន់នូវអាកប្បកិរិយាឱ្យបានត្រឹមត្រូវ” ហើយលោកនិយាយថា លោកអាច “ចាប់ជនក្បត់ដោយមានភស្តុតាងគ្រប់គ្រាន់នៅកណ្តាលអធ្រាត្របាន”។ ទោះបីយ៉ាងណាក៏ដោយ លោកថ្លែងថា “យើងមិនញុះញង់ និងលើកទឹកចិត្តឱ្យប្រជាជនប្រើកម្លាំងទេ”។ ក្រោយការផ្សាយបន្តផ្ទាល់រួចមក វីដេអូនោះត្រូវបានបង្ហោះដោយស្វ័យប្រវត្តិនៅលើទំព័រហ្វេសប៊ុករបស់លោក ហ៊ុន សែន ដែលមានអ្នកមើលប្រហែល 600,000 ដង **ហើយ**ត្រូវបានចែករំលែកតិចជាង 3,000 ដង។ សុន្ទរកថានេះ ត្រូវបានផ្សព្វផ្សាយដោយប្រព័ន្ធផ្សព្វផ្សាយនៅក្នុងស្រុក និងក្នុងតំបន់។ នាពេលប៉ុន្មានឆ្នាំថ្មីៗនេះ កម្ពុជាត្រូវបានគេឃើញថា មានការកើនឡើងនូវការបង្ក្រាបទៅលើគណបក្សប្រឆាំងនយោបាយ សកម្មជន អ្នកដឹកនាំសហជីព និងប្រព័ន្ធផ្សព្វផ្សាយសំខាន់ៗផ្សេងៗ។

អ្នកប្រើប្រាស់បីនាក់ បានរាយការណ៍វីដេអូនោះចំនួនប្រាំដងចំពោះការបំពានលើ ស្តង់ដារស្តីពីហិង្សា និងការញុះញង់ក្នុងសហគមន៍របស់ Meta។ ស្តង់ដារនេះហាមប្រាម “[ការ]គំរាមនានាដែលនាំឱ្យមានការរងរបួសធ្ងន់ធ្ងរ (អំពើហិង្សាកម្រិតមធ្យម-កម្រិតធ្ងន់ធ្ងរ)” រួមមាន “[សេច]ក្តីថ្លែងការនានាដែលមានគោលបំណងក្នុងការប្រព្រឹត្តអំពើហិង្សា”។
ជាទូទៅ, ខ្លឹមសារត្រូវបានកំណត់ជាអាទិភាពសម្រាប់ការត្រួតពិនិត្យឡើងវិញដោយមនុស្ស ដោយ

ផ្អែកលើកម្រិតធ្ងន់ធ្ងរ និន្នាការ និងលទ្ធភាពនៃការបំពានលើគោលការណ៍ខ្លឹមសាររបស់វា។ ក្នុងករណីនេះ បច្ចេកវិទ្យារបស់ក្រុមហ៊ុន Meta បានបិទដោយស្វ័យប្រវត្តិលើការរាយការណ៍របស់អ្នកប្រើប្រាស់ទាំងនេះ ដោយមិនចាំបាច់មានការត្រួតពិនិត្យឡើងវិញដោយមនុស្សទេ ពីព្រោះការរាយការណ៍ទាំងនេះមិនត្រូវបានចាត់ទុកជាអាទិភាព និងមិនមានការពិនិត្យឡើងវិញនៅក្នុងរយៈពេល 48 ម៉ោងនៃការរាយការណ៍ឡើយ។ ក្រោយពេលអ្នកប្រើប្រាស់ដែលបានរាយការណ៍ពីខ្លឹមសារនេះធ្វើការតវ៉ា វីដេអូនេះក៏ត្រូវបានពិនិត្យឡើងវិញដោយអ្នកត្រួតពិនិត្យ ពីរនាក់ ដែលពួកគេបានរកឃើញថាខ្លឹមសារនេះមិនបានបំពានលើគោលការណ៍របស់ក្រុមហ៊ុន Meta ទេ។ ក្នុងពេលជាមួយគ្នានេះដែរ ខ្លឹមសារនេះត្រូវបានបញ្ជូនឡើងទៅកាន់អ្នកជំនាញផ្នែកគោលការណ៍ និងខ្លឹមសារវិវាទនៅក្នុងក្រុមហ៊ុន Meta ។ អ្នកជំនាញទាំងនោះបានកំណត់ថា វាបានបំពានលើស្តង់ដាស្តីពីហិង្សា និងការញុះញង់ក្នុងសហគមន៍ ប៉ុន្តែបានកំណត់នូវមុខងារ newsworthiness allowance ទៅលើខ្លឹមសារដើម្បីអនុញ្ញាតឱ្យវីដេអូនេះនៅតែស្ថិតនៅលើផ្លេតហ្វម។ មុខងារ newsworthiness allowance អនុញ្ញាតឱ្យខ្លឹមសារដែលបំពានគោលការណ៍នឹងនៅតែបន្តស្ថិតនៅលើផ្លេតហ្វមរបស់ក្រុមហ៊ុន Meta ដោយសារតែគុណតម្លៃរបស់ខ្លឹមសារមានផលប្រយោជន៍សម្រាប់សាធារណៈច្រើនជាងហានិភ័យដែលអាចបង្កឱ្យមានគ្រោះថ្នាក់។ អ្នកប្រើប្រាស់ម្នាក់ក្នុងចំណោមអ្នកប្រើប្រាស់នានាដែលបានរាយការណ៍ខ្លឹមសារនេះ បានប្តឹងតវ៉ាលើការសម្រេចចិត្តរបស់ក្រុមហ៊ុន Meta ទៅក្រុមប្រឹក្សាភិបាល។ ជាការដាច់ដោយឡែក ក្រុមហ៊ុន Meta បានបញ្ជូនករណីនេះបន្តទៅក្រុមប្រឹក្សាភិបាល ដោយលើកឡើងថា វាពាក់ព័ន្ធនឹងតុល្យភាពមួយដ៏លំបាករវាងគុណតម្លៃ
“សុវត្ថិភាព” និងសំឡេង” នៅក្នុងការកំណត់ថា នៅពេលណាដែលគួរអនុញ្ញាតឱ្យខ្លឹមសារសុន្ទរកថាដែលមានលក្ខណៈហិង្សាដែលបានថ្លែងដោយអ្នកដឹកនាំនយោបាយម្នាក់ អាចស្ថិតនៅលើផ្លេតហ្វមបាន។ ក្រុមហ៊ុន Meta បានស្នើសុំការណែនាំពីក្រុមប្រឹក្សាភិបាលអំពីរបៀបអនុវត្តស្តង់ដារស្តីពីហិង្សា និងការញុះញង់ក្នុងសហគមន៍ទៅលើសេចក្តីថ្លែងការណ៍ណាដែលភ្ជាប់ជាមួយនឹងការគំរាមគំហែងដែលបណ្តាអ្នកដឹកនាំនយោបាយបានថ្លែងនៅក្រៅជម្លោះ ឬស្ថានភាពវិបត្តិនោះ។

ក្រុមប្រឹក្សាភិបាលបានជ្រើសរើសករណីនេះ ដោយសារវាបានលើកឡើងនូវសំណួរពាក់ព័ន្ធនឹងគោលការណ៍មួយចំនួន ទាក់ទងនឹងរបៀបដែលក្រុមហ៊ុនគួរចាត់ចំណាត់ការបែបណាលើសុន្ទរកថាដែលបណ្តាអ្នកដឹកនាំនយោបាយបានថ្លែង ហើយបានបំពានលើគោលការណ៍ខ្លឹមសាររបស់ក្រុមហ៊ុន Meta។ ការនេះមានការពាក់ព័ន្ធជាពិសេសនៅក្នុងបរិបទនៃការគំរាមគំហែងបែបហិង្សាដែលអាចកើតមានឡើង ចំពោះគូបដិបក្ខនយោបាយនានា ពីសំណាក់អ្នកដឹកនាំជាតិម្នាក់ ដែលធ្វើឡើងនៅមុនការបោះឆ្នោតនៅក្នុងប្រទេសដែលមានប្រវត្តិនៃអំពើហិង្សា និងភាពមិនប្រក្រតីនៅក្នុងការបោះឆ្នោត។ ករណីនេះបានចូល

នៅក្នុងអាទិភាពរបស់ក្រុមប្រឹក្សាភិបាល ក្នុងផ្នែក “ការប្រើប្រាស់របស់រដ្ឋាភិបាលលើផ្លែតហ្វមរបស់ក្រុមហ៊ុន Meta” ហើយវាក៏ពាក់ព័ន្ធនឹងអាទិភាពនៃ “ការបោះឆ្នោត និងសេរីភាពពលរដ្ឋ” ផងដែរ។

ក្រុមប្រឹក្សាភិបាលនឹងអរគុណចំពោះមតិសាធារណៈណាដែលលើកឡើងអំពីៈ

- ស្ថានភាពនយោបាយ និងសិទ្ធមនុស្សនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាផលប៉ះពាល់ដែលអាចកើតមានពីសុន្ទរកថារបស់លោក ហ៊ុន សែន ទៅលើការបោះឆ្នោតដែលនឹងប្រព្រឹត្តទៅនៅខែកក្កដា ឆ្នាំ 2023។
- ការសម្របសម្រួលរបស់ក្រុមហ៊ុន Meta លើខ្លឹមសារដែលបានបង្ហោះដោយតួអង្គរដ្ឋជាពិសេសដោយធ្វើការសម្រួលខ្លឹមសារដែលពួកគេបង្ហោះអំពីតួអង្គអ្នកប្រឆាំង និងអត្តន័យដែលជាប់ទាក់ទិនរបស់វា។
- ទំនួលខុសត្រូវរបស់ក្រុមហ៊ុន Meta នៅក្នុងការបោះឆ្នោត និងឱកាសសំខាន់ៗសម្រាប់ការចូលរួមក្នុងនយោបាយ ជាពិសេសនៅក្នុងស្ថានភាពដែលមានដូចនៅប្រទេសកម្ពុជា ដែលជាកន្លែងដែលផ្លែតហ្វមរបស់ក្រុមហ៊ុន Meta កាន់តែមានសារៈសំខាន់បន្ថែមទៀតចំពោះប្រជាជន និងជាកន្លែងដែលមានការរឹតត្បិតលើប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក។
- លក្ខណៈវិនិច្ឆ័យអ្វីខ្លះដែលគួរមានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត ក្នុងការកំណត់ “ newsworthiness allowance” ចំពោះខ្លឹមសារដែលអាចបង្កឱ្យមានគ្រោះថ្នាក់ ដែលបានបង្ហោះដោយបណ្តាអ្នកដឹកនាំនយោបាយ។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ក្រុមប្រឹក្សាភិបាលអាចចេញអនុសាសន៍នានាទាក់ទងនឹងគោលការណ៍ដល់ក្រុមហ៊ុន Meta។ ខណៈដែលអនុសាសន៍ទាំងនោះមិនមានលក្ខណៈចាប់បង្ខំអនុវត្តនោះទេ ក្រុមហ៊ុន Meta ត្រូវតែធ្វើការឆ្លើយតបក្នុងរយៈពេល 60 ថ្ងៃ។ ចំពោះករណីបែបនេះ ក្រុមប្រឹក្សាភិបាលសូមស្វាគមន៍រាល់បណ្តាមតិសាធារណៈទាំងឡាយដែលមានការលើកឡើងនូវអនុសាសន៍នានាដែលពាក់ព័ន្ធនឹងករណីនេះ។